Declassified to Public
12 June 2020

លេខ៖ D 334/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត

Office of the Co-Investigating Judges
Bureau des co-juges d'instruction

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 29 / 03 / 2017
ម៉ោង (Time/Heure): 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ៖ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ ៖ ថ្ងៃ ២៩ ខែ មីនា ឆ្នាំ ២០១៧

ភាសា ៖ ខ្មែរ និង អង់គ្លេស

ចំណាត់ថ្នាក់ឯកសារ ៖ សម្ងាត់

## សេចក្តីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**

មុំ លុច្ស
Richard ROGERS
Göran SLUITER

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉េន ពៅ

Laure DESFORGES NZEPA
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARATI

## I. ប្រវត្តិនីតិវិធី

១. ករណីខ្វែងយោបល់រវាងសហចៅក្រមស៊ើបអង្កេត (“ស.ច.ស”) នៅក្នុងសំណុំរឿងនេះ បាន ចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ និងថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧។

២. នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ ស.ច.ស បានជូនដំណឹងភាគីទាំងអស់អំពីការបិទកិច្ចស៊ើបសួរ ប្រឆាំង អោ អាន ដោយរំឭកភាគីទាំងអស់ថា ភាគីមានរយៈពេល ១៥ ថ្ងៃចាប់ពីពេល ជូនដំណឹងនេះ ដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែម(“សេចក្តីជូនដំណឹង”) ហើយបានបង្គាប់ ឱ្យបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំង អោ អាន ចេញពីសំណុំរឿង ០០៤[1]។ នៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៦ ស.ច.ស. អន្តរជាតិ បានពន្យារពេលកំណត់ដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរ បន្ថែមរហូតដល់ថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧[2]។

៣. នៅថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៦ មេធាវីការពារក្តី អោ អាន (“មេធាវីការពារក្តី”) បានដាក់ *សំណើសុំឱ្យដាក់ឯកសារមួយចំនួនពាក់ព័ន្ធនឹង Henri Locard ទៅក្នុងសំណុំរឿង* (“សំណើទី ១”)[3]។ សហព្រះរាជអាជ្ញាមិនបានដាក់ការឆ្លើយតបទៅនឹងសំណើទី ១ ទេ។

៤. នៅថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិ (“ស.ព.អ”) បានដាក់ *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរដើម្បីដាក់ផែនទី និង ឯកសារនៃសំណុំរឿង ០០២ ទៅក្នុងសំណុំរឿង ០០៤/២* (“សំណើទី ២”)[4]។ មេធាវីការពារក្តី មិនបាន ដាក់សារណាតបទៅនឹងសំណើទី ២ ទេ។

៥. នៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧ មេធាវីការពារក្តី បានដាក់ *សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១៣* (“សំណើទី៣”) ដែលក្នុងសំណើនេះ មេធាវីការពារក្តី បានស្នើសុំ ស.ច.ស ឱ្យ

---

[1]សំណុំរឿង ០០៤ ឯកសារ D334 *សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន* ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦។ សំណុំរឿង ០០៤ ឯកសារ D334/1 *ដីកាសម្រេចបំបែកនីតិវិធី ប្រឆាំងនឹង អោ អាន ចេញពីសំណុំរឿង ០០៤* ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦។

[2]សំណុំរឿង០០៤/២ ឯកសារ D340/1 *ដីកាសម្រេចលើសំណើរបស់ អោ អាន សុំពន្យារពេលកំណត់ដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែមក្រោយពីមានការជូនដំណឹងអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង* ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៦។

[3]សំណុំរឿង ០០៤/២ ឯកសារ D339 *សំណើសុំឱ្យដាក់ឯកសារមួយចំនួនពាក់ព័ន្ធនឹង Henri Locard ទៅក្នុងសំណុំរឿង* ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៦។

[4]សំណុំរឿង ០០៤/២ ឯកសារ D342 *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរដើម្បីដាក់ផែនទី និងឯកសារនៃសំណុំរឿង ០០២ ទៅក្នុងសំណុំរឿង ០០៤/២* ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៦។

ផ្តល់ជូនការវិភាគកំហុសមួយចំនួនដែលបានចោទនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ[5]។ សហព្រះរាជអាជ្ញាមិនបានដាក់ការឆ្លើយតបទៅនឹងសំណើទី ៣ ទេ។

៦. នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ ស.ច.ស.អន្តរជាតិ បានដាក់ *ដីកាសម្រេចលើសំណើសុំឱ្យដាក់ឯកសារមួយចំនួនពាក់ព័ន្ធនឹង Henri Locard ទៅក្នុងសំណុំរឿង* ("ដីកាសម្រេចទី ១") ជាការឆ្លើយតបទៅនឹងសំណើទី ១ ហើយក៏បានដាក់*ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរដើម្បីដាក់ផែនទី និងឯកសារនៃសំណុំរឿង ០០២ ទៅក្នុងសំណុំរឿង ០០៤/០២* ("ដីកាសម្រេចទី ២") ជាការឆ្លើយតបទៅនឹងសំណើទី ២[6]។

៧. នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៧ ស.ច.ស.អន្តរជាតិ បានដាក់ *ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១៣ របស់ អោ អាន* ("ដីកាសម្រេចទី ៣") ជាការឆ្លើយតបទៅនឹងសំណើទី ៣[7]។

## II. ពិភាក្សា

### ក. កិច្ចស៊ើបសួរបន្ថែមដែលបានបំពេញរួច

៨. យោងតាមដីកាសម្រេចទី ១ អត្ថបទសារព័ត៌មានមួយមានក្នុងសំណុំរឿងរួចហើយ ដែលពាក់ព័ន្ធនឹងការវាយតម្លៃលើភាពអាចទុកចិត្តបាន និងភាពអាចជឿជាក់បានលើភស្តុតាងរបស់ Henry Locard ត្រូវបានដាក់ចូលក្នុងសំណុំរឿងនេះ។[8]

៩. យោងតាមដីកាសម្រេចទី ២ (i) ឯកសារដែលផ្តល់ព័ត៌មានទាក់ទងនឹងប្រព័ន្ធភូមិសាស្ត្រ និងរដ្ឋបាលរបស់របបកម្ពុជាប្រជាធិបតេយ្យ ឬក៏បង្ហាញឱ្យឃើញថាពាក់ព័ន្ធនឹងការចោទប្រកាន់អំពីគោលនយោបាយរៀបការដោយបង្ខំ ការប្រើប្រាស់ការដ្ឋាន និងសហករណ៍ និងការ

---

[5]សំណុំរឿង ០០៤/២ ឯកសារ D345 *សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១៣ របស់ អោ អាន* ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧។

[6]សំណុំរឿង ០០៤/២ ឯកសារ D339/1 *ដីកាសម្រេចលើសំណើសុំឱ្យដាក់ឯកសារមួយចំនួនពាក់ព័ន្ធនឹង Henri Locard ទៅក្នុងសំណុំរឿង* ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៧។ សំណុំរឿង ០០៤/២ ឯកសារ D342/1 *ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរដើម្បីដាក់ផែនទី និងឯកសារនៃសំណុំរឿង ០០២ ទៅក្នុងសំណុំរឿង ០០៤/២* ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៧។

[7]សំណុំរឿង ០០៤/២ ឯកសារ D345/1 *ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១៣ របស់ អោ អាន* ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៧។

[8]ដីកាសម្រេចទី ១ កថាខណ្ឌ ១៥, ១៧។

ដាក់គោលដៅលើក្រុមមនុស្សមួយចំនួន និង (ii) សន្និកម្មពីការជំនុំជម្រះក្តីសំណុំរឿង ០០២/២ ដែលបន្ថែមលើភស្តុតាងរបស់សាក្សីដែលមាននៅក្នុងសំណុំរឿងរួចហើយ[9] ត្រូវបានដាក់ក្នុងសំណុំរឿងនេះ។

១០. សំណើទី ៣ មិនបានស្ថិតនៅក្នុងប្រភេទសំណើសុំបំពេញ *"កិច្ចស៊ើបសួរបន្ថែម"* ដែលអាចស្នើសុំបានយោងតាមវិធានផ្ទៃក្នុង ៦៦(១)ទេ ហេតុនេះ ការបំពេញកិច្ចដែលបានធ្វើឡើងទាក់ទងនឹងសំណើទី ៣ មិនត្រូវចាត់ទុកថាជាសំណើសុំបំពេញកិច្ចស៊ើបសួរទេ[10]។

១១. ក្រោយពីអស់សុពលភាពនៃរយៈពេលកំណត់ដែលបានពន្យារពេលដើម្បីដាក់សំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម និងការបញ្ចប់ការបំពេញកិច្ចស៊ើបសួរបន្ថែមយោងតាមដីកាសម្រេចទី ១ និងដីកាសម្រេចទី ២ យើងយល់ឃើញថា កិច្ចស៊ើបសួរប្រឆាំង អោ អាន បានបញ្ចប់ហើយ។

## ខ. សេចក្តីជូនដំណឹង និងពេលវេលាដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែមក្រោយពីមានសេចក្តីជូនដំណឹងយោងតាមវិធានផ្ទៃក្នុង ៦៦(១)

១២. វិធានផ្ទៃក្នុង ៦៦(១) តម្រូវថា បន្ទាប់ពីចេញសេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ ភាគីទាំងអស់ត្រូវមានរយៈពេល ១៥ ថ្ងៃ ដើម្បីស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម។ វិធានផ្ទៃក្នុងមិនបានចែងច្បាស់អំពីសេចក្តីជូនដំណឹងក្រោយពីមានសេចក្តីជូនដំណឹងយោងតាមវិធានផ្ទៃក្នុង ៦៦(១) បន្ទាប់ពីបានបំពេញកិច្ចកិច្ចស៊ើបសួរបន្ថែមដែលបានស្នើសុំឡើយ ហើយក៏មិនបានចែងច្បាស់ថាតើត្រូវផ្តល់ជូនពេលវេលាបន្ថែម("ពេលវេលាបន្ថែម")ដើម្បីស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមដែរឬអត់នោះទេ។ តាមសំអាងហេតុខាងក្រោមនេះ យើងជឿជាក់ថា វិធានផ្ទៃក្នុង៦៦(១) តម្រូវឱ្យចេញសេចក្តីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរ ប៉ុន្តែ វិធាននេះតម្រូវឱ្យទុករយៈពេលមួយតែប៉ុណ្ណោះដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែមក្រោយពីមានសេចក្តីជូនដំណឹងលើកទី ១។

១៣. យើងជឿជាក់ថា ការចេញសេចក្តីជូនដំណឹងលើកទី២ ដើម្បីផ្តល់ភាពច្បាស់លាស់ជូនភាគីទាំងអស់ ថាកិច្ចស៊ើបសួរប្រឆាំងជនត្រូវចោទ បានបញ្ចប់(ម្តងទៀត)ហើយ ប្រសិនបើ និងបន្ទាប់ពីបានបំពេញកិច្ចលើសំណើសុំបំពេញកិច្ចស៊ើបសួររួចហើយ និងដើម្បីដៅចំណុចពេលវេលាឱ្យបានច្បាស់លាស់ដែលតាមច្បាប់ ដែលភាគីទាំងអស់អាចរំពឹងថានឹងមានចេញដីកា

[9] ដីកាសម្រេចទី ២ កថាខណ្ឌ ១៣-១៤។

[10] ដីកាសម្រេចទី ៣ កថាខណ្ឌ ៩។

បញ្ជូនសំណុំរឿងទៅពិនិត្យ យោងតាមវិធានផ្ទៃក្នុង ៦៦(៤) ប្រសិនបើមិនមានកាលៈទេសៈដែលអាចឱ្យពន្យារពេលចេញដីកាបែបនេះដោយសារសំអាងហេតុផ្សេងទេ។

១៤. ច្បាប់ទូទៅរបស់កម្ពុជា ដែលយើងត្រូវតែយកជាមូលដ្ឋាន ប្រសិនបើវិធានផ្ទៃក្នុងមិនមានបទប្បញ្ញត្តិច្បាស់លាស់ជាងនេះនោះទេ បានគាំទ្រយើងឱ្យបកស្រាយថា មិនតម្រូវឱ្យមានរយៈពេលបន្ថែមឡើយ។ យើងកត់សម្គាល់ថា មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងយ៉ាងច្បាស់អំពីសំណើសុំបំពេញកិច្ចស៊ើបសួរដែលធ្វើដោយព្រះរាជអាជ្ញាតែប៉ុណ្ណោះ តាមមាត្រា ១៣២ និងមិនមែនធ្វើឡើងដោយមេធាវីការពារក្ដី តាមមាត្រា ១៣៣ ទេ នៅពេលដែលសេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរបានផ្ញើជូនភាគីហើយ[11]។ ខណៈដែលគេអាចអះអាងថា តាមការបកស្រាយតាមន័យត្រង់ កិច្ចស៊ើបសួរបានបិទបញ្ចប់ នៅពេលចេញដីកាដំណោះស្រាយតែប៉ុណ្ណោះ(មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា)។ ហេតុនេះ ពាក្យពេចន៍នៃមាត្រា ១៣៣ អាចអនុវត្តបានរហូតដល់ចំណុចពេលវេលាក្នុងកិច្ចដំណើរការនីតិវិធី ហើយអនុញ្ញាតឱ្យមេធាវីការពារក្ដី ដាក់សំណើរហូតដល់ពេលចេញដីកាដំណោះស្រាយ។ មាត្រា ១៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ក៏ចែងដូចគ្នានេះដែរសម្រាប់ព្រះរាជអាជ្ញា។ យើងយល់ឃើញថា មាត្រា ២៤៦ គឺជាបទប្បញ្ញត្តិពិសេសសម្រាប់ស្ថានភាពក្រោយពីមានសេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ ដែលបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរណាមួយធ្វើឡើងដោយមេធាវីការពារក្ដី តាមវិធានជាទូទៅនៃមាត្រា ១៣៣ បន្ទាប់ពីមានសេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ។ បើមិនអញ្ចឹងទេ ការយោងយ៉ាងច្បាស់ដល់សិទ្ធិរបស់ព្រះរាជអាជ្ញា តាមមាត្រា ១៣២ ក្នុងពេលតែមួយមិនបានយោងដោយស្មើភាពដល់សិទ្ធិរបស់មេធាវីការពារក្ដី តាមមាត្រា ១៣៣ នឹងមិនមានខ្លឹមសារអ្វីទេ។ ការខកខានមិនចែងផ្ដល់សិទ្ធិឱ្យមេធាវីសុំបំពេញកិច្ចស៊ើបសួរថ្មីក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ មិនមែនជាកំហុសធម្មតាទេ ហើយនេះវាប៉ះពាល់ធ្ងន់ធ្ងរដល់ជំហររបស់ជនត្រូវចោទ។ ក្នុងន័យនេះ វិធានផ្ទៃក្នុង មានការកែលម្អរួចហើយបើធៀបជាមួយនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដោយក្នុងនោះ វិធានផ្ទៃក្នុងអនុញ្ញាតឱ្យមេធាវីការពារក្ដី និងភាគីផ្សេងទៀត ដាក់សំណើក្នុងរយៈពេល ១៥ ថ្ងៃ។

១៥. ហេតុនេះ យើងជឿជាក់ថា មិនចាំបាច់ផ្ដល់ជូនពេលវេលាបន្ថែមទៀតទេ ប្រសិនបើមិនមានកាលៈទេសៈពិសេស ដូចជា ឯកសារថ្មីដាក់ចូលក្នុងសំណុំរឿងមានចំនួនច្រើនសន្ធឹកសន្ធាប់ ហើយតម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដោយភាគីប៉ះពាល់ដើម្បីធ្វើការវិភាគ ដែល

---

[11] *សូមមើល កំណត់សម្គាល់លើក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា* បោះពុម្ពលើកទី ២ ឆ្នាំ ២០១៥ ទំព័រ ៩៨ [ភាសាអង់គ្លេស]។

នេះនាំឱ្យមានការលំបាកយ៉ាងខ្លាំងប្រសិនភាគីដែលប៉ះពាល់ មិនមានពេលវេលាបន្ថែមទៀតទេ ដើម្បីស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរថ្មីដែលកើតចេញពីការវិភាគនោះ។

១៦. នៅក្នុងសំណុំរឿងមុន យើងបានផ្តល់ជូនភាគីនូវពេលវេលាបន្ថែមដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែម ក្រោយពីពេលជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ យើងរកឃើញថា ឯកសារមួយចំនួនចាំបាច់ត្រូវធ្វើចំណាត់ឡើងវិញពីសម្ងាត់បំផុត ទៅសម្ងាត់[12] ដោយសារថា មូលហេតុតែមួយគត់ដែលនាំឱ្យមានការយឺតយ៉ាវក្នុងការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ បណ្តាលមកពីកំហុសឆ្គងនៅការិយាល័យសហចៅក្រមស៊ើបអង្កេត។ ករណីនេះគឺខុសគ្នា។ ហេតុនេះ យើងសូមមិនធ្វើការពិភាក្សា វិធីសាស្ត្រសម្រាប់ដោះស្រាយ ករណីមានកិច្ចស៊ើបសួរដែលបានស្នើសុំឱ្យបំពេញ ស្របគ្នានឹងកិច្ចស៊ើបសួរតាមការផ្តួចផ្តើមគំនិតផ្ទាល់ខ្លួនរបស់យើងក្រោយពីជូនដំណឹងអំពីការបិទកិច្ចស៊ើសួរ។

**តាមសំអាងហេតុខាងលើ យើង៖**

១៧. **ជូនដំណឹង** ភាគីទាំងអស់ថា យើងយល់ឃើញថា កិច្ចស៊ើបសួរប្រឆាំង អោ អាន បានបញ្ចប់ហើយ។

១៨. **ជូនដំណឹង** ភាគីទាំងអស់ ថា តាមវិធានផ្ទៃក្នុង មិនតម្រូវឱ្យទុកពេលសម្រាប់កិច្ចស៊ើបសួរបន្ថែមទៀតទេ ហេតុនេះ មិនផ្តល់ជូនពេលវេលាបន្ថែមទៀតទេ។

ភ្នំពេញ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧

**សហចៅក្រមស៊ើបអង្កេត**
Co-Investigating Judges
Co-juge d'instruction

**ចៅក្រម យូ ប៊ុនឡេង** **ចៅក្រម** **Michael BOHLANDER**

[12] សំណុំរឿង ០០៤ ឯកសារ D286/7 *ដីកាសម្រេចបំបែកសំណុំរឿងទាក់ទង អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤* ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ កថាខណ្ឌ ៦។